ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

---

# កិច្ចព្រមព្រៀង

ថ្ងៃទី២៦ ខែ សីហា ឆ្នាំ២០២៣ វេលាម៉ោង១០:00នាទីព្រឹក នៅក្រុមហ៊ុន មីឈើ(ខេមបូឌា)ហ្វាមេន ឯ.ក បានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាពលោកស្រី XU GENXIAN ជានាយកក្រុមហ៊ុន ស្តីពីការព្យួរកិច្ចសន្យាការងារមួយរយៈដោយគ្មានអ្នកបញ្ជាទិញ។

សមាសភាពចូលរួមប្រជុំមាន ៖

1-ភាគីតំណាងរោងចក្រ

-លោកស្រី XU GENXIAN ជានាយករោងក្រ

-លោកស្រី ស៊ុនគាវ ជារដ្ឋបាល

-លោកស្រី រិត សេងហ៊ាង ជាអ្នកកត់ត្រា

2-ភាគីតំណាងកម្មករនិយោជិត

-លោកស្រី ម៉ៅលក្ខិណា

-លោកស្រី ប្រាក់ សារ៉ំ

-លោកស្រី យុនសុខា

-លោក យែម យ៉ុង

-លោក ទូច ព្រីល

ក្រោយពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក ភាគីទាំងពីរបានឈានដល់ ព្រមព្រៀងគ្នាដូច ខាងក្រោម ៖

1-ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត ចំនួនសរុប ៧៩៨នាក់ ក្នុងរយៈពេល ២៩ ថ្ងៃ ចាប់ពីថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២៣ ។

2-ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុននឹងផ្តល់នូវ ប្រាក់លើកទឹកចិត្តចំនួន ៣០ដុល្លាក្នុង១ខែសំរាប់កម្មករម្នាក់ៗហើយក្រុមហ៊ុននឹងគោរពទៅតាមប្រកាសរបស់ក្រសួងការងារនៃ ព្រះរាជាណាចក្រកម្ពុជា ។

៣-ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតចំនួន ៣០ ដុល្លារអាមេរិកហើយប្រាក់ឧបត្ថម្ភនេះនិងបើកជូន កម្មករនោយោជិកនៅថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ២០២៣។

៤-ចប់ការព្យួរការងារកម្មករនិយោជិតត្រូវមកចូលធ្វើការនៅកន្លែងដើមវិញ តាមតួនាទីភារកិច្ចរបស់ខ្លួន។

៥-ប្រសិនបើក្រុមហ៊ុនមានវត្ថុធាតុដើមចូលវិញ ក្រុមហ៊ុននឹងហៅបងប្អូនកម្មករនិយោជិតមកធ្វើការជាធម្មតា។

ក្រោយប្រជុំនេះចប់សព្វគ្រប់នៅវេលាម៉ោង១០:៤៥ នាទីព្រឹក នាថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០២៣ ដំដែលក្រោមបរិយាកាសរីករាយ។

Scanned with CamScanner

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០២៣

**បានឃើញនិងឯកភាព**

**នាយកក្រុមហ៊ុន**

**XU GENXIAN**

បានឃើញនឹងឯកភាព

តំណាងកម្មករ

លោកស្រី ម៉ៅលក្ខិណា , លោកស្រី ប្រាក់ សារ៉ំ

លោក យែម យ៉ុង លោក ទូចព្រឹល លោកស្រី យុនសុខា

Scanned with CamScanner